# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៥៧៣ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៧

**ជម្រាបមក**

**លោកនាយកសារព័ត៌មានអាណាចក្រខ្មែរ**

**កម្មវត្ថុ ៖** ករណីសារព័ត៌មានអាណាចក្រខ្មែរចុះផ្សាយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧ ក្រោមចំណងជើងថា "មហិច្ឆតារបស់លោក វេង សាខុន ប៉ងរំលោភ ដីប្រជាពលរដ្ឋប្រគល់ឲ្យក្រុមហ៊ុន ឌីប៉ូ ត្រូវបរាជ័យ"។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោកនាយកជ្រាបថា ការចុះផ្សាយរបស់សារព័ត៌មានអាណាចក្រខ្មែរក្រោមចំណងជើងថា មហិច្ឆតារបស់លោក វេង សាខុន ប៉ងរំលោភដីប្រជាពលរដ្ឋប្រគល់ឲ្យក្រុមហ៊ុន ឌីប៉ូ ត្រូវបរាជ័យ គឺជាការចុះផ្សាយដោយមិនបានសិក្សាស្វែងយល់ពីនីតិវិធីច្បាប់ ពុំគោរពក្រមសីលធម៌វិជ្ជាជីវៈជាអ្នកសារព័ត៌មាន ដែលទង្វើនេះធ្វើឡើងក្នុងគោលដៅ ញុះញង់ បង្កើតជម្លោះរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុន បន្ទុះបង្អាប់ ធ្វើឲ្យខូចកិត្យានុភាពរាជរដ្ឋាភិបាល ធ្វើឲ្យរាំងស្ទះដល់ការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល និងការចូលរួមពីវិស័យឯកជន ក្នុងទិសដៅបម្រើឲ្យមហិច្ឆតាឈ្មួញដី និងជនខិលខូចមួយចំនួនដែលមិនមែនជាប្រជាពលរដ្ឋរស់នៅនិងអាស្រ័យផលក្នុងមូលដ្ឋាននេះពិតប្រាកដ ដោយពួកគេទាំងនោះចង់រំលោភយកដីសាធារណៈរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ឆ្លើយតបនឹងអត្ថបទចុះផ្សាយរបស់សារព័ត៌មានអាណាចក្រខ្មែរនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការបំភ្លឺដូចតទៅ៖

១-ផ្ទៃដីទំហំ១ ៦៩០ហិកតា គឺ*ជាផ្ទៃដីដែលរាជរដ្ឋាភិបាលឯកភាពជាគោលការណ៍* ឲ្យក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍វិនិយោគសម្រាប់អភិវឌ្ឍគម្រោងវិនិយោគ សុខ សែនជ័យ លើវិស័យកសិកម្ម តាមលិខិតលេខ១៧៩៣ សជណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

២-បន្ទាប់ពីទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលលើផ្ទៃដីទំហំ ១ ៦៩០ហិកតា *ជាដីសាធារណៈរបស់រដ្ឋ* ក្រុមហ៊ុនត្រូវសហការជាមួយក្រសួងជំនាញ និងអាជ្ញាធរដែនដីបំពេញនូវនីតិវិធីមួយចំនួនទៀតដូចជា ការចុះសិក្សាកាត់ចេញផលប៉ះពាល់ផ្សេងៗ រួមមាន៖ ផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ តំបន់រក្សាទុក (ដីអាងទឹក ដីព្រៃ ដីជំនឿ ដីផ្លូវ.....)។ ការចុះអនុវត្តការងារនេះត្រូវបានជួបបញ្ហារាំងស្ទះព្រោះមានបញ្ហាស្មុគស្មាញជាច្រើនដូចជា៖ ១/ មានឈ្មួញទិញលក់ដី ២/ មានជនខិលខូចចលនាប្រជាពលរដ្ឋប្រឆាំងនឹងគម្រោងអភិវឌ្ឍន៍ ៣/ មានមតិខ្វែងគ្នារវាងក្រសួង ស្ថាប័នជំនាញ ។ ការងារនេះត្រូវអូសបន្លាយរហូតដល់ឆ្នាំ២០១៧ ទើបរាជរដ្ឋាភិបាលសម្រេចចេញលិខិតលេខ*៨៩ស ជណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧* របស់ទីស្តីការគណៈរដ្ឋមន្ត្រី មានខ្លឹមសារសង្ខេបដូចខាងក្រោម៖

ក.ប្រគល់ជូនក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ បន្តសកម្មភាពធ្វើការដាំដុះស្រូវប្រដេញទឹកនៅលើផ្ទៃដី ៩៨០ហិកតាបន្តទៀត។

ខ.ប្រគល់ជូនក្រុមការងារចំពោះកិច្ចបន្តជំរុញការចុះវាស់វែង និងផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋឱ្យបានជ្រះស្រឡះ ក្នុងទិសដៅដោះស្រាយបញ្ហាជម្លោះដីធ្លីដែលមានសភាពរ៉ាំរ៉ៃក្នុងតំបន់នេះ។

គ.ក្រោយពេលផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋចប់សព្វគ្រប់ ផ្ទៃដីនៅសល់ជូនក្រុមហ៊ុនធ្វើវិនិយោគឲ្យស្របតាមនីតិវិធីជាធរមាន ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចុះកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចជាមួយក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia. Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

៣-អនុវត្តតាមខ្លឹមសារលិខិតលេខ៨៩ សជណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី រួមទាំងអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ និងអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងព្យាយាមអនុវត្តឲ្យស្របតាមនីតិវិធីច្បាប់ដោយក្នុងនោះបាន៖

ក.ស្នើសុំបង្វែរផ្ទៃដីទំហំ ១ ៦៩០ហិកតាដែលជាផ្ទៃដីកម្មវត្ថុនៃគោលការណ៍អនុញ្ញាត និងកើតមានទំនាស់ ***ជាដីសាធារណៈរបស់រដ្ឋ*** ឲ្យទៅជា ***ដីឯកជនរបស់រដ្ឋ*** តាមរយៈការស្នើសុំធ្វើអនុបយោគពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ខ.ការស្នើសុំអនុបយោគលើផ្ទៃដីទំហំ ១ ៦៩០ហិកតា មកជា ***ដីឯកជនរបស់រដ្ឋ*** គឺក្នុងគោលបំណងយកដីនេះមកចាត់ចែងប្រើប្រាស់ដូចជា៖

- កាត់ជូនប្រជាពលរដ្ឋនូវផ្ទៃដីអាស្រ័យផលពិតប្រាកដ និងផ្ទៃដីកាន់កាប់ស្របច្បាប់ (មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ)។ កន្លងមកការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុជូនប្រជាពលរដ្ឋនៅតំបន់នេះ ធ្វើឡើងលើដី ***សាធារណៈរបស់រដ្ឋ*** ពុំទាន់បានសមស្របនឹងនីតិវិធីច្បាប់នៅឡើយ។
- កាត់ចេញនូវផ្ទៃដីមួយចំនួនដើម្បីរក្សាទុកដូចជា ដីរាងទឹក ដីបឹង ដីទ្រនាប់អូរស្ទឹង ដីចំណីផ្លូវសាធារណៈ ។ល។
- កំណត់ទំហំផ្ទៃដីដែលនៅសល់សម្រាប់ឲ្យក្រុមហ៊ុនធ្វើការវិនិយោគ។

*ក្នុងន័យនេះ មិនមានន័យថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើសុំអនុបយោគលើទំហំផ្ទៃដី ១ ៦៩០ហិកតាសម្រាប់យកមកប្រគល់ឲ្យក្រុមហ៊ុនធ្វើការវិនិយោគលើទំហំផ្ទៃដីទាំង ១ ៦៩០ហិកតានោះទេ គឺសម្រាប់យកមកប្រើប្រាស់ដូចបានជម្រាបជូនខាងលើក្នុងគោលបំណងតែមួយគត់ គឺដើម្បីបំពេញនីតិវិធីឲ្យស្របតាមផ្លូវច្បាប់ និងដោះស្រាយឲ្យបានជ្រះស្រឡះនូវបញ្ហាទំនាស់ដែលកើតមានឡើងរ៉ាំរ៉ៃនៅក្នុងតំបន់នេះតាមខ្លឹមសារលិខិតលេខ៨៩ សជណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។*

អាស្រ័យហេតុនេះ សូមលោកនាយកជ្រាបនិងធ្វើការកែតម្រូវតាមការគួរ។

ត.ប រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**អគ្គលេខាធិការ**

ឡោ រស្មី

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
-សាលាខេត្តកណ្ដាល
"ដើម្បីជូនជ្រាប"
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
"ដើម្បីជ្រាប និងមុខការ"
-ឯកសារ កាលប្បវត្តិ